# គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទដំហាន ២

## សេចក្តីសង្ខេបស្តីពីក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

### អំពីគម្រោង

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (GKC) បានទទួលហិរញ្ញប្បទានពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដើម្បីជួយផ្តល់ហិរញ្ញប្បទានដល់គម្រោង ពង្រឹងសមត្ថភាពផលិតភាពជនបទដំហ៊ាន ២ ឬ NRRPCP-2 ដែលត្រូវបានគេកំណត់ថាជាអាទិភាពក្នុងការពង្រឹងការតភ្ជាប់ទីជនបទរបស់រដ្ឋាភិបាល។ គោលបំណងនៃគម្រោងនឹងសម្រេចបានតាមរយៈការរក្សា និងពន្លឿនការចំណាយលើហេដ្ឋារចនាសម្ព័ន្ធជនបទ បង្កើតការងាររយៈពេលខ្លី និងបង្កើតប្រាក់ចំណូល កសាងសមត្ថភាពការងារក្នុងស្រុក និងអ្នកម៉ៅការថ្នាក់ជាតិ ដើម្បីធានាបាននូវការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទប្រកបដោយគុណភាពតាមស្តង់ដារជាតិដែលបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍ និងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ ការរៀនសូត្រ និងការចែករំលែកចំណេះដឹងក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗនៃគម្រោង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទ និងការផ្តល់សេវាជនបទ។

គម្រោងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ផ្លូវជនបទយ៉ាងហោចណាស់ ៤១២ គីឡូម៉ែត្រ ដែលស្ថិតនៅក្នុងខេត្តចំនួន ១០ គឺកំពង់ឆ្នាំង ត្បូងឃ្មុំ ព្រៃវែង បាត់ដំបង កំពង់ធំ តាកែវ កណ្តាល ស្វាយរៀង កំពត និងកែប ។ ផ្លូវដែលនឹងត្រូវបានស្តារឡើងវិញទាំងនេះត្រូវបានរំពឹងថា នឹងធ្វើឲ្យប្រសើរឡើងនូវការធ្វើដំណើរពេញមួយឆ្នាំសម្រាប់ប្រជាជននៅទីជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធដែលនឹងកែលម្អនេះ នឹងជួយដល់ការធ្វើដំណើរ ការដឹកជញ្ជូនផលិតផលកសិកម្ម និងការតភ្ជាប់ទៅកាន់មណ្ឌលសុខភាព ទីផ្សារ និងសាលារៀន ។ វាត្រូវបានព្យាករណ៍ថាមានប្រជាជននៅជនបទប្រមាណ ១,000,000 នាក់ នឹងទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោងរួមទាំងក្រុមងាយរងគ្រោះ ដូចជាស្ត្រី កុមារ យុវជនគ្មានការងារធ្វើ ជនចាស់ជរា ជនមានពិការភាព ពលករចំណាកស្រុកដែលត្រឡប់មក

វិញ និងសហគមន៍ជនជាតិដើមភាគតិច ។ លើសពីនេះ គម្រោងនេះត្រូវបានរំពឹងថានឹងបង្កើតការងាររយៈពេលខ្លីប្រមាណ ៥០,០០០ កន្លែង និងគាំទ្រដល់ការចូលរួមរបស់ក្រុមហ៊ុនម៉ៅការសាងសង់ក្នុងស្រុក ដើម្បីពង្រឹងសមត្ថភាពក្នុងស្រុក ។

## គោលបំណង

ឯកសារក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និង សង្គម មានគោលការណ៍ ក្រឹត្យក្រម ការណែនាំ និង និតិវិធីច្បាស់លាស់សម្រាប់វាយតម្លៃពីហានិភ័យ និង ផលប៉ះពាល់បរិស្ថាន និង សង្គមក្នុងការអនុវត្តគម្រោង។ ឯកសារនេះមានផែនការ និង វិធានការក្នុងការកាត់បន្ថយផលប៉ះពាល់តាមអនុគម្រោង ដោយត្រូវរៀបចំការប៉ាន់ស្មានទំហំថវិកាសម្រាប់ដោះស្រាយដែលអង្គភាពអនុវត្តគម្រោងត្រូវទទួលខុសត្រូវរៀបចំឯកសារពាក់ព័ន្ធ នឹងផលប៉ះពាល់ និង ហានិភ័យរបស់គម្រោងដោយអនុលោមតាមឯកសារក្របខ័ណ្ឌបរិស្ថាន និង សង្គមរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។

## ក្របខ័ណ្ឌបរិស្ថាន និង សង្គម បានកំណត់ដូចខាងក្រោម៖

- ពិព៌ណនាសង្ខេបអំពីគម្រោង
- ក្របខ័ណ្ឌច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគម្រោងអោយមានសង្គតិភាពជាមួយក្របខ័ណ្ឌបរិស្ថាន និង សង្គមរបស់ធនាគារវិនិយោគលម្អហេដ្ឋារចនាសម្ព័ន្ធអាស៊ីដោយត្រូវវិភាគស្វែងរកចំណុចខ្វះចន្លោះ។
- វិភាគអំពីសក្តានុពល ហានិភ័យ/ផលប៉ះពាល់បរិស្ថាន និង សង្គម និងវិធានការកាត់បន្ថយ
- រៀបចំនីតិវិធីក្នុងការកំណត់ និង រៀបចំផែនការគ្រប់គ្រងបរិស្ថាន និង សង្គម (ESMP) និងរៀបចំរចនាសម្ព័ន្ធក្រុមការងារដើម្បីអនុវត្តន
- ការវាយតម្លៃសមត្ថភាពដើម្បីអនុវត្តឯកសារ ESMF និង ឧបករណ៍ផ្សេងៗទៀត
- រៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ា
- ការតាមដាន និង រាយការណ៍
- រៀបចំផែនការថវិកា

ឯកសារស្តីពីការគ្រប់គ្រងបរិស្ថាន និង សង្គម និងគំរូក្នុងឧបសម្ព័ន្ធ គឺជាមូលដ្ឋានក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និង សង្គម ការបញ្ជាក់ពីនីតិវិធីក្នុងករណីរកឃើញវត្ថុបូរាណ នីតិវិធីគ្រប់គ្រងការងារ និង ក្រមសីលធម៌ និង ការត្រួតពិនិត្យ។

ក្រៅពីឯកសារព្រាងស្តីពីក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និង សង្គម ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំការពិគ្រោះយោបល់ និង ផ្សព្វផ្សាយនូវឯកសារមួយចំនួនទៀតតាមគោលការណ៍នៃឯកសារក្របខ័ណ្ឌបរិស្ថាន និង សង្គមផងដែរ ដូចជា៖ (i) ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ (ii) ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (iii) ផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ។ ចំពោះឯកសារលម្អិតខាងលើអាចស្វែងរកបាននៅក្នុងឯកសារវាយតម្លៃគម្រោងរបស់ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។

## ផលប៉ះពាល់ និងវិធានការកាត់បន្ថយ

ដំណាក់កាលនៃការរៀបចំគម្រោង ខណៈខ្សែផ្លូវជនបទ ពុំទាន់ត្រូវបានកំណត់ជាក់លាក់ ទំហំផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គមនៅពុំទាន់អាចកំណត់បានច្បាស់លាស់ និង សុក្រឹត្យឡើយ ប៉ុន្តែអាចធ្វើការប៉ាន់ស្មាន និងត្រូវធ្វើបច្ចុប្បន្នភាពក្រោយពេលខ្សែផ្លូវជនបទ ត្រូវបានកំណត់ច្បាស់លាស់។ ផ្អែកតាមឯកសារក្របខ័ណ្ឌបរិស្ថាន និងសង្គម សម្រាប់គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទនេះត្រូវអនុវត្តតាមវិធានការណ៍កាត់បន្ថយដូចខាងក្រោម៖

ក. គិតទុកជាមុន ជៀសវាងកត្តាហានិភ័យ និង ផលប៉ះពាល់ដែលអាចកើតឡើង

ខ. ករណីមិនអាចជៀសបាន ត្រូវកាត់បន្ថយហានិភ័យ និង ផលប៉ះពាល់ក្នុងកម្រិតអប្បរមា

គ. ករណីនៅមានផលប៉ះពាល់ត្រូវផ្តល់សំណងតាមលក្ខណៈបច្ចេកទេស និង នីតិវិធីហិរញ្ញវត្ថុ

គម្រោងនេះនឹងនាំមកនូវផលប្រយោជន៍ជាច្រើនដល់សហគមន៍ដូចជា៖ កាត់បន្ថយពេលវេលាធ្វើដំណើរទៅកាន់សាលារៀន មណ្ឌលសុខភាព និងទីកន្លែងទទួលសេវាសាធារណៈផ្សេងទៀត បង្កើនឳកាសទីផ្សារ និងការងារ ធ្វើអោយការធ្វើដំណើរមានភាពរលូនក្នុងរដូវវស្សា ធ្វើអោយមានភាពប្រសើរឡើងនូវសុវត្ថិភាពចរាចរណ៍ និងបរិយាកាស/បរិស្ថានល្អ ដោយសារផ្លូវមិនហុយ និង មិនបែកផុក។ បញ្ជីហានិភ័យសំខាន់ៗ និងវិធានការកាត់បន្ថយផលប៉ះពាល់រួមមាន៖ គុណភាពទឹក និង បរិយាកាស គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់នៅកន្លែងការងារ ការហូរចូលកម្លាំងពលកម្ម និង ការកាន់កាប់ដីធ្លី។ ឧបសម្ព័ន្ធទី ១៣៖ ESCoP ទូទៅសម្រាប់ផ្លូវជនបទ

## នីតិវិធីរបស់ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមមានគោលបំណងដើម្បីគ្រប់គ្រងរាល់ផលប៉ះពាល់អវិជ្ជមានទាំងឡាយដែលកើតឡើងដោយសារគម្រោង ត្រូវរៀបចំជាឯកសារគោលការណ៍ណែនាំដើម្បីវាយ

ការណ៍ជូនក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងស្ថាប័ន្ធពាក់ព័ន្ធ និងក្រុមហ៊ុនដែលទទួលកិច្ចសន្យាសាងសង់ សំដៅការរៀបចំផែនការលម្អិតក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង តាមនីតិវិធី និងវិធានដូចមានចែងក្នុងឯកសារបរិស្ថាន និងសង្គមរបស់គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ។ ឯកសារនេះ ក៏ជាត្រីយ៍វិស័យក្នុងកិច្ចដំណើការនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៅពេលខ្សែផ្លូវជនបទត្រូវបានកំណត់ច្បាស់លាស់។ ឯកសារគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គមត្រូវបានរៀបចំឡើងដើម្បីធានាថាៈ

- ការស្ថាបនាផ្លូវជនបទបានគិតគូអំពីបញ្ហាបរិស្ថាន និងសង្គម ពិសេសសម្រាប់ប្រជាពលរដ្ឋដែលត្រូវទទួលរងផលប៉ះពាល់ពីគម្រោងដោយផ្ទាល់ (វិជ្ជមាន និងអវិជ្ជមាន)
- ការស្ថាបនាផ្លូវបទបានគិតគូអំពីបញ្ហាយ៉េនឌ័រ និងវប្បធម៌សង្គម និងបញ្ហាសង្គមនានាដែលកើតឡើងនៅតាមខ្សែផ្លូវរបស់គម្រោង
- ក្នុងដំណាក់កាលរៀបចំគម្រោងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម នឹងអាចកើតមានឡើងនៅអំឡុងពេលអនុវត្តគម្រោង ហើយត្រូវរៀបចំផែនការត្រួតពិនិត្យ និងវិធានការសមស្របដើម្បីអនុវត្តនូវ វិធីសាស្រ្ត នីតិវិធី និងឧបករណ៍នានា ដូចមានចែងនៅក្នុងឯកសារផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ឯកសារផែនការជនជាតភាគតិច (IPP) និងឯកសារផែនការដោះស្រាយផលប៉ះពាល់ (RPF)
- ឧបករណ៍ដែលត្រូវយកមកប្រើប្រាស់ដើម្បីគ្រប់គ្រងបញ្ហាបរិស្ថាន និងសង្គមរួមមានៈ ផែនការគ្រប់ គ្រងបរិស្ថាន និងសង្គម (ESMP) ផែនការជនជាតភាគតិច (IPP) និងផែនការដោះស្រាយផលប៉ះពាល់ (RPF)
- ចំណុចសំខាន់នៃផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ រួមទាំងយន្តការដោះស្រាយបណ្តឹងតវ៉ានឹង ត្រូវបានយកមកប្រើប្រាស់សម្រាប់រាល់សកម្មភាពរបស់គម្រោង
- ឧបករណ៍បរិស្ថាន និងសង្គមត្រូវរៀបចំឲ្យមានសង្គតិភាពគ្នារវាងក្របខ័ណ្ឌបរិស្ថាននិងសង្គមរបស់ធនាគារកែលម្អហេដ្ឋារចនាសម្ព័ន្ធអាស៊ី ជាមួយនឹងក្របខ័ណ្ឌច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា
- ការរៀបចំគម្រោងត្រូវពិចារណាអំពីគោលការណ៍ដូចមានចែងនៅក្នុងឯកសារក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ព្រមទាំងនីតិវិធីនីមួយៗក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និង សង្គម
- យន្តការក្នុងការកំណត់រកផលប៉ះពាល់ និងហានិភ័យនានា ត្រូវបានរៀបចំក្នុងករណីស្គាល់ខ្សែផ្លូវ
- ត្រូវរៀបចំនីតិវិធី និងការទទួលខុសត្រូវសម្រាប់ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម បានរៀបរាប់អំពីនីតិវិធីក្នុងការកំណត់ការរៀបចំផែនការគ្រប់គ្រង បរិស្ថាន និងសង្គម ដោយរួមមានទាំងជំហានលំអិត ព័ត៌មានចាំបាច់ ការទទួលខុសត្រូវ និងតម្រូវការ បណ្តុះបណ្តាលដល់បុគ្គលិកគម្រោងដែលទទួលបន្ទុកត្រួតពិនិត្យផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។ ត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធអនុវត្តគម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធអន្តរក្រសួង និងសម្រាប់ទីប្រឹក្សាបច្ចេកទេស និងអ្នកទទួលការសាងសង់ផ្លូវ។

## ការពិគ្រោះយោបល់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

សម្រាប់សមាសភាពនៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ នឹងត្រូវរៀបចំសកម្មភាពពិគ្រោះយោបល់ និងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ដូចមានចែងនៅក្នុងឯកសារផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីធានាថាសហគមន៍ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវបានជ្រាប និងចូលរួមក្នុង ដំណើការរបស់គម្រោង សំដៅប្រមូលនូវធាតុប្រកបដោយបរិយាប័ន្ន។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិភាក្សាលើសេចក្តីព្រាងឯកសារស្តីពីបរិស្ថាន និងសង្គម ជាមួយក្រសួងស្ថាប័ន្ធពាក់ព័ន្ធមួយចំនួននៅកម្រិតថ្នាក់ជាតិ ហើយឯកសារក្របខ័ណ្ឌបរិស្ថាន និងសង្គម ត្រូវបានផ្សព្វផ្សាយជាសាធារណៈ នៅក្នុងគេហទំព័រ ឬបណ្ណាល័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងគេហទំព័ររបស់វិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។

## ការដោះស្រាយបណ្តឹងតវ៉ា

យន្តការបណ្តឹងតវ៉ា ស្វែងរកវិធីសាស្រ្តដោះស្រាយឲ្យទាន់ពេលវេលានូវរាល់ទុក្ខកង្វល់ប្រជាពលរដ្ឋដែល កើតឡើងដោយសារការអនុវត្តគម្រោង តាមរយៈការប្រើប្រាស់វប្បធម៌ដោះស្រាយបញ្ហាប្រកបដោយការ យោគយល់គ្នា និងឈានទៅរកការយល់ព្រមដោយមិនចាំបាច់ផ្តល់សំណងណាមួយ។ យន្តការនេះ អាចត្រូវបានអនុវត្តជូនចំពោះបុគ្គលណាមួយ បើសិនគេគិតថាគម្រោងនេះ នឹងធ្វើឲ្យប៉ះពាល់បាត់បង់ ប្រយោជន៍ធ្ងន់ធ្ងរដល់គេផ្ទាល់ ដល់សហគមន៍ បរិស្ថាន ឬប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគេ ដោយពួកគេអាចបញ្ជូននូវរាល់មតិយោបល់ និងសំណូមពរមកគម្រោងបាន។ យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានពិពណ៌មានលំអិតនៅក្នុងឯកសារគម្រោងស្តីពីផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធនឹងគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ រំពឹងថាអាចមានបណ្តឹងតវ៉ា ៤ប្រភេទ៖

- បណ្តឹងតវ៉ាពាក់ព័ន្ធបញ្ហាដីធ្លី ដែលត្រូវអនុវត្តតាមផែនការដោះស្រាយផលប៉ះពាល់តាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បណ្តឹងតវ៉ាពាក់ព័ន្ធការអនុវត្តគម្រោងផ្ទាល់ (ផលប៉ះពាល់សង្គម និងបរិស្ថាន សុខភាព សុវត្ថិភាពចរាចរណ៍)
- បណ្តឹងតវ៉ាពាក់ព័ន្ធនឹងជនជាតិដើមភាគតិច
- និងវិវាទនានាពាក់ព័ន្ធនឹងកម្មករ (លំអិតក្នុងឧបសម្ព័ន្ធទី១៣)

## ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍

ការត្រួតពិនិត្យ គឺជាវិធីសាស្រ្តក្នុងការធានាថា វិធានការកាត់បន្ថយកំពុងត្រូវបានយកមកអនុវត្តប្រកបដោយប្រសិទ្ធិភាព។ ត្រូវរៀបចំធ្វើរបាយការណ៍ត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាសជាចាំបាច់ដើម្បី៖

- កែលម្អនូវការចំណុចខ្វះខាតក្នុងការអនុវត្តការគ្រប់គ្រងបរិស្ថាន និងសង្គម
- ធានាប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃបរិស្ថាន និងសង្គម
- បង្កើតទម្រង់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមផ្អែកលើសមិទ្ធកម្ម
- ផ្តល់នូវឱកាសដើម្បីរាយការណ៍ពីលទ្ធផលនៃការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នៅពេលត្រូវរៀបចំឯកសារ ESMP នាពេលអនាគត និងឯកសារពាក់ព័ន្ធគម្រោងផ្សេងទៀត។

កំឡុងពេលអនុវត្តអនុគម្រោង មន្រ្តីបរិស្ថាន និងសង្គមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នឹងរៀបចំប្រតិទិន ប្រចាំខែចុះត្រួតពិនិត្យគម្រោងលើផែនការគ្រប់គ្រងបរិស្ថាន និងបរិស្ថាន ដើម្បីកំណត់ពីវិធីសាស្រ្តក្នុងការ កាត់បន្ថយផលប៉ះពាល់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្រុមការងារបរិស្ថាន និងសង្គមរបស់ ក្រសួងអភិវឌ្ឍន៍ជនបទ រួមជាមួយទីប្រឹក្សាបច្ចេកទេស និងចុះត្រួតពិនិត្យរួមគ្នាដើម្បីធានាថាវិធានការនៃ ការកាត់បន្ថយផលប៉ះពាល់ដែលមានចែងនៅក្នុងក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ត្រូវបានយកមក ប្រើប្រាស់ដោយអ្នកអនុវត្តគម្រោងដូចជា អ្នកទទួលការសាងសង់ និងស្ថាប័នទទួលខុសត្រូវនានា។ មន្រ្តីបរិស្ថាន និងសង្គមនឹងចុះត្រួតពិនិត្យយន្តការដោះស្រាយបណ្តឹងតវ៉ា លើដំណើរការដោះស្រាយផល ប៉ះពាល់បញ្ហាដីធ្លីក្នុងគម្រោងធានាថាបងប្អូនជនជាតិដើមភាគតិចត្រូវបានទទួលអត្ថប្រយោជន៍ប្រកប ដោយសមធម៌ និងត្រូវរៀបចំឯកសារចាំបាច់មួយចំនួនដើម្បីអនុវត្តផែនការជាមួយភាគីពាក់ព័ន្ធ និងការ ផ្សព្វផ្សាយអំពីសកម្មភាពរបស់គម្រោង។